01182561

**Declassified to Public**
**05 May 2021**

លេខ៖ D286

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 01 / 2016
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥**

ភាសា ៖ **អង់គ្លេស និង ខ្មែរ**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីអ៊ឹម ចែម**

ប៊ិត ស៊ាងលឹម
John R.W.D. Jones

**មេធាវីការពារក្តីយឹម ទិត្យ**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”)បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយបើកការស៊ើបអង្កេតប្រឆាំង អ៊ឹម ចែម ហើយស្នើដាក់បទចោទប្រកាន់ផ្សេងៗប្រឆាំងគាត់[1]។ បន្ទាប់មក ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនបួនដោយចោទថា អ៊ឹម ចែម ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត[2]។

២. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ បន្ទាប់ពីបានចុះហត្ថលេខាលើករណីខ្វែងយោបល់គ្នាជាមួយនឹងសហចៅក្រមស៊ើបអង្កេត(ស.ច.ស)ជាតិរួចមក អតីត ស.ច.ស.អន្តរជាតិ Mark Harmon បានដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ពីបទរំលោភលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (មនុស្សឃាត) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត[3]

---

[1]សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០-១១-២០០៨* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ១១៩។ សំណុំរឿង០០៤ ឯកសារD1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។ សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០៨។

[2]សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ២៣។ សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤។ សំណុំរឿង ០០៤ ឯកសារ D254/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមុះ* ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៨។ សំណុំរឿង ០០៤ ឯកសារ D272/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ កថាខណ្ឌ ១៤។

[3]សំណុំរឿង ០០៤ ឯកសារ D239 *ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤ ឯកសារ D239.1 *ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម* ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥។

។ មេធាវីការពារក្តីរបស់ អ៊ឹម ចែម (“មេធាវីការពារក្តី”) បានដាក់បណ្តឹងឧទ្ធរណ៍ទៅ អង្គបុរេជំនុំជម្រះ[4] ហើយឥឡូវនេះកំពុងរង់ចាំសាលដីកា។

៣. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ស.ច.ស បានស្នើសុំសារណាពីភាគីទាំងអស់ ស្តីពីថាតើ អ៊ឹម ចែម គួរត្រូវចាត់ទុកថា ជា“មេដឹកនាំជាន់ខ្ពស់”ម្នាក់ ឬស្ថិតក្នុងចំណោម“*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩*”[5]។ មេធាវីការពារក្តី ស.ព.អ និងសហព្រះរាជអាជ្ញាជាតិ បានដាក់សារណារៀងៗខ្លួន[6]។ ទាំងមេធាវីការពារក្តី ទាំងសហព្រះរាជអាជ្ញាជាតិ បានបញ្ជាក់ថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់[7] ហើយក៏មិនស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដូច្នេះគាត់ស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[8]។ ស.ព.អ បានបញ្ជាក់ថា អ៊ឹម ចែម

---

[4]សំណុំរឿង ០០៤ ឯកសារ D239/1/2 *បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រី ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥។

[5]សំណុំរឿង ០០៤ ឯកសារ D251 *សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា “មេដឹកនាំជាន់ខ្ពស់” ឬស្ថិតក្នុងចំណោម “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”* ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥។

[6]សំណុំរឿង ០០៤ ឯកសារ D251/4 *សេចក្តីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្តីពីបញ្ហាថាតើ អ្នកស្រីគួរត្រូវបានចាត់ទុកថាជា“មេដឹកនាំជាន់ខ្ពស់” ឬស្ថិតក្នុងចំណោម“ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥(“សារណារបស់មេធាវីការពារក្តី”)។ សំណុំរឿង ០០៤ ឯកសារ D251/5 *សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា“មេដឹកនាំជាន់ខ្ពស់” ឬ ក្នុងចំណោម“ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”ដែរឬយ៉ាងណាចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ (“សារណារបស់ ស.ព.អ”)។ សំណុំរឿង ០០៤ ឯកសារ D251/6 *សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥(“សារណារបស់សហព្រះរាជអាជ្ញាជាតិ”)។

[7]សារណារបស់ មេធាវីការពារក្តី កថាខណ្ឌ ៦០។ សារណារបស់ សហព្រះរាជអាជ្ញាជាតិ កថាខណ្ឌ ១៣។

[8]សារណារបស់ ស.ព.អ កថាខណ្ឌ ៤៤។

មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែ គាត់ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដូច្នេះគាត់ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[9]។

៤. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស បានជូនដំណឹង ភាគីទាំងអស់ និងមេធាវីរបស់ភាគីទាំងអស់ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ហើយបានផ្តល់ពេលវេលាជូនភាគីទាំងអស់ ក្នុងរយៈពេល ១៥ថ្ងៃ ដើម្បីស្នើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម[10]។

## II. ពិភាក្សា

៥. ដោយផ្អែកលើភស្តុតាងដែលប្រមូលបាននៅក្នុងកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម បច្ចុប្បន្ននេះ យើង មាននិន្នាការចង់លើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ដោយសារកង្វះយុត្តាធិការបុគ្គល។ យោងតាមវិធានផ្ទៃក្នុង ៦៦(៥) សហព្រះរាជអាជ្ញា នឹងមានពេលវេលាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរជាលាយល័ក្ខអក្សរ និងមានសំអាងហេតុមុនពេលយើង ចេញដីកាដំណោះស្រាយ តាមវិធាន ៦៧។

៦. វិធានផ្ទៃក្នុង ២១(៤) តម្រូវថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវបញ្ចប់ក្នុងរយៈពេលមួយសមស្រប។ ដើម្បីសម្រេចគោលដៅនេះ បច្ចុប្បន្ននេះ យើងមាននិន្នាការចង់បំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម។ ការធ្វើបែបនេះនឹងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម ដោយមិនចាំបាច់រង់ចាំលទ្ធផលនៃកិច្ចស៊ើបសួរដែលនៅសេសសល់នៅក្នុងសំណុំរឿង 00៤ ទេ។

**តាមសំអាងហេតុខាងលើ យើង[11]៖**

[9]សារណារបស់ ស.ព.អ កថាខណ្ឌ ៤៥ និង ៥១។

[10]សំណុំរឿង 00៤ ឯកសារ D285 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

[11] ខណៈដែលសហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញសេចក្តីជូនដំណឹងនេះរួមគ្នា សហចៅក្រមស៊ើបអង្កេតជាតិ កត់សម្គាល់ទុកជាឯកសារថា ឯកសារទាំងឡាយ នៃសំណុំរឿង 00៤ ត្រូវចុះលេខរៀងបន្តពីលេខឯកសារចុងក្រោយមុនពេលការលាលែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk ដោយមិនរាប់បញ្ចូលឯកសារទាំងអស់ដែលត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet។

៧. **ជូនដំណឹង** ភាគីទាំងអស់ ថា បច្ចុប្បន្ននេះ យើង មានទិន្នាការចង់លើកលែងការចោទប្រកាន់ ប្រឆាំង អ៊ឹម ចែម ដោយសារកង្វះយុត្តាធិការបុគ្គល។

៨. **ជូនដំណឹង** ភាគីទាំងអស់ ថា បច្ចុប្បន្ននេះ យើងមានទិន្នាការចង់បំបែក កិច្ចដំណើរការនីតិវិធី ប្រឆាំង អ៊ឹម ចែម។

៩. **អញ្ជើញ** ភាគីទាំងអស់ សុំដាក់នៅត្រឹមថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ នូវសារណាដែលខ្លួនអាចមានអំពីការបំបែក កិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juges d'instruction

យូ ប៊ុនឡេង Michael BOHLANDER